# អេម៉ុស Amos

ហោរាអេម៉ុសគឺជាអ្នកគង្វាលម្នាក់មកពីអាណាចក្រខាងត្បូង(យូដា)។ ហោរាអេម៉ុសមកពីអាណាចក្រខាងត្បូង ប៉ុន្តែគាត់បានប្រកាសព្រះរាជសារនៅក្នុងអាណាចក្រខាងជើង (អ៊ីស្រាអែល)។ ជំពូក៧បានចែងថា សង្ឃនៅត្រង់បេត-អែលចាត់ទុកហោរាអេម៉ុសជាជនក្បត់ជាតិ ហើយប្រាប់គាត់អោយត្រឡប់ទៅស្រុកកំណើតវិញ ប៉ុន្តែហោរាអេម៉ុសពន្យល់ថា គាត់មិនដែលរំពឹងចង់ធ្វើជាហោរាទេ តែព្រះបានហៅគាត់ ហើយបានប្រទានព្រះរាជសាររបស់ទ្រង់ដល់គាត់ ដើម្បីប្រកាសដល់អ៊ីស្រាអែល។

ហោរាអេម៉ុសបានប្រកាសថា ព្រះគឺជាចៅក្រមនៃជាតិសាសន៍ទាំងអស់ រួមទាំងអ៊ីស្រាអែលផងដែរ ប៉ុន្តែទំនាក់ទំនងពិសេស ដែលព្រះមានជាមួយនឹងអ៊ីស្រាអែល មិនមានន័យថា អ៊ីស្រាអែលនឹងមិនប្រឈមចំពោះការវិនិច្ឆ័យរបស់ព្រះនោះទេ។ ផ្ទុយទៅវិញ ព្រះនឹងវិនិច្ឆ័យអ៊ីស្រាអែលដោយខ្នាតគំរូខ្ពស់បំផុត។

## កាលៈទេសៈតាមប្រវត្តិសាស្ត្រនៅសម័យអេម៉ុស Historical background to Amos

ហោរាអេម៉ុសបានប្រកាសព្រះរាជសារបន្ទាប់ពីអ៊ីស្រាអែលត្រូវបែងចែកជាពីរ គឺអាណាចក្រខាងជើង ហៅថា អ៊ីស្រាអែល និងអាណាចក្រខាងត្បូង ហៅថា យូដា នៅក្នុងកំឡុងឆ្នាំ៧៦០មុនគ.ស។ ហោរាអេម៉ុសបានប្រកាសព្រះរាជសារដល់សង្គមមួយ ដែលមានភាពចម្រុងចម្រើននិងកាន់តាមសាសនា។ អ៊ីស្រាអែលមានភាពសំបូរសប្បាយក្នុងកំឡុងការគ្រប់គ្រងរបស់ស្តេចយេរ៉ូបោមទី២ ប៉ុន្តែ សាសនារបស់ពួកគេបានត្រលប់ជាឥតប្រយោជន៍ទេ ពីព្រោះពួកគេបានព្រងើយកន្តើយចំពោះក្រិត្យវិន័យរបស់ព្រះ។ នៅក្នុងស្ថានភាពនោះ ហោរាអេម៉ុសបានប្រកាសព្រះរាជសាររបស់ព្រះប្រឆាំងនឹងសង្គម ព្រមទាំងសាសនានៅក្នុងអ៊ីស្រាអែល គឺគាត់បានព្រមានប្រជាជនអ៊ីស្រាអែលថា ពួកគេមានទោសហើយ ព្រោះព្រះមិនគាប់ព្រះទ័យចំពោះការថ្វាយបង្គំរបស់ពួកគេទេ (៥:២១) សេចក្តីលោភលន់របស់ពួកគេកំពុងបំផ្លាញសង្គម ហើយពួកគេមិនការពារអ្នកក្រីក្រនិងអ្នកទន់ខ្សោយទេ (២:៦-៧)។ ពួកគេនឹងត្រូវទទួលទណ្ឌកម្មធ្ងន់ធ្ងរ។ ហោរាអេម៉ុសក៏បានប្រកាសព្រះបន្ទូលរបស់ព្រះទាស់នឹងអំពើបាបរបស់យូដាផងដែរ។

## គម្រោង Outline

ព្រះនឹងវិនិច្ឆ័យជាតិសាសន៍ជុំវិញ (១:១-២:៥)

ព្រះនឹងវិនិច្ឆ័យអ៊ីស្រាអែល ដែលជារាស្ត្ររបស់ទ្រង់ផ្ទាល់ (២:៦-៦:១៤)

និមិត្តអំពីសេចក្តីវិនាស និងព្រះបន្ទូលនៃសេចក្តីសង្ឃឹម (៧:១-៩:១៥)

## របៀបអានកណ្ឌអេម៉ុស How to read Amos

ដើម្បីឲ្យយល់និងអនុវត្តកណ្ឌអេម៉ុសអោយបានត្រឹមត្រូវ សំខាន់យើងត្រូវយល់កណ្ឌនេះនៅក្នុងបរិបទដើមរបស់វានៅក្នុងប្រវត្តិសាស្ត្រ និងនៅក្នុងបរិបទនៃព្រះគម្ពីរទាំងមូល។ ដើម្បីយល់បែបនេះបាន យើងត្រូវឆ្លើយនឹងសំនួរប្រាំមួយដូចខាងក្រោម។

១. តើកណ្ឌអេម៉ុសទាក់ទងនឹងកណ្ឌផ្សេងៗទៀតដែលមានក្នុងព្រះគម្ពីរមុនកណ្ឌនេះយ៉ាងដូចម្តេច?

២. តើគោលបំណងរបស់កណ្ឌអេម៉ុសសំរាប់អ្នកអានដើមដំបូងក្នុងសម័យព្រះគម្ពីរសញ្ញាចាស់គឺជាអ្វី?

៣. តើកណ្ឌអេម៉ុសទាក់ទងនឹងកណ្ឌផ្សេងៗទៀតដែលមានក្នុងព្រះគម្ពីរបន្ទាប់ពីកណ្ឌនេះយ៉ាងដូចម្តេច?

៤. តើកណ្ឌនេះបង្រៀនយើងអ្វីខ្លះអំពីព្រះជាម្ចាស់?

៥. តើកណ្ឌនេះបង្រៀនយើងអ្វីខ្លះអំពីមនុស្ស?

៦. តើកណ្ឌនេះអនុវត្តមកកាន់គ្រីស្ទបរិស័ទសព្វថ្ងៃយ៉ាងដូចម្តេច?

## ១. តើកណ្ឌអេម៉ុសទាក់ទងនឹងកណ្ឌផ្សេងៗទៀតដែលមានក្នុងព្រះគម្ពីរមុនកណ្ឌនេះយ៉ាងដូចម្តេច?

ព្រះគម្ពីរគឺមានសាច់រឿងធំមួយ ដែលពន្យល់អំពីផែនការរបស់ព្រះចាប់តាំងពីការបង្កបង្កើតរហូតដល់ការបង្កបង្កើតជាថ្មី។ ដំបូងទ្រង់បានបង្កើតគ្រប់សព្វយ៉ាងល្អ ដោយមានអ័ដាមនិងអេវ៉ានៅក្នុងសួនច្បារអេដែន។ ពួកគេគឺជារាស្ត្ររបស់ព្រះ នៅក្នុងទីកន្លែងរបស់ព្រះ ក្រោមការគ្រប់គ្រងនិងក្នុងព្រះពររបស់ព្រះ។ នេះគឺជាគោលដៅរបស់ព្រះសំរាប់ការបង្កបង្កើត។ ពួកគេមិនបានស្តាប់បង្គាប់ ហើយត្រូវបានបណ្តេញចេញពីសួនច្បារ ដែលជាទីបរិសុទ្ធរបស់ព្រះ។ ព្រះគម្ពីរនិយាយអំពីផែនការរបស់ព្រះ ក្នុងការសង្គ្រោះមនុស្សចេញពីលទ្ធផលនៃការបះបោរនេះ ហើយស្តារនគររបស់ទ្រង់ឡើងវិញ ដែលជារាស្ត្ររបស់ព្រះ នៅក្នុងទីកន្លែងរបស់ព្រះ ក្រោមការគ្រប់គ្រងនិងព្រះពររបស់ព្រះ។ ដូច្នេះ ព្រះបានជ្រើសរើសអ័ប្រាហាំ ហើយបានសន្យាថា ទ្រង់នឹងធ្វើអោយគាត់ក្លាយជាជាតិសាសន៍មួយដ៏ធំ ហើយពួកគេនឹងទទួលបានទឹកដីសន្យា។ តាមរយៈពូជពង្សរបស់អ័ប្រាហាំ ព្រះនឹងប្រទានពរដល់លោកិយ (លោកុប្បត្តិ ១២:៣)។ ពួកគេត្រូវតែជារាស្ត្ររបស់ព្រះ នៅក្នុងទីកន្លែងរបស់ព្រះ ក្រោមការគ្រប់គ្រងនិងព្រះពររបស់ព្រះ ។ ទ្រង់នឹងគង់ក្នុងចំណោមពួកគេ ដូច្នេះអ៊ីស្រាអែលនៅក្នុងទឹកដីសន្យាគឺអេដែនថ្មីដែលជាទីបរិសុទ្ធថ្មី (សូមមើល លោកុប្បត្តិ ១៣:១០)។ ព្រះបានមានបន្ទូលនៅក្នុងនិក្ខមនំ ១៩:៤-៦ ថា ទ្រង់បានជ្រើសរើសអ៊ីស្រាអែលធ្វើជារាស្ត្រពិសេសរបស់ទ្រង់ ហើយក្នុងចោទិយកថា ៤ ចែងថា ពួកគេត្រូវធ្វើជាពន្លឺដល់ជាតិសាសន៍ដទៃទាំងអស់។ ចោទិយកថា ២៨ ប្រកាសបណ្តាសារបស់សម្ព័ន្ធមេត្រីថា បើសិនអ៊ីស្រាអែលមិនស្មោះត្រង់ចំពោះព្រះ និងមិនធ្វើតាមការត្រាស់ហៅរបស់ព្រះចំពោះខ្លួនទេ នោះព្រះនឹងបញ្ជូនពួកគេចេញពីទឹកដី។ នៅក្នុង២សាំយូអែល ៧ ព្រះបានមានព្រះបន្ទូលសន្យាដ៏អស្ចារ្យ ជាមួយនឹងស្តេចដាវីឌថា ពូជពង្សមួយរបស់ស្តេចដាវីឌនឹងសោយរាជ្យនៅលើបល្ល័ង្កជារៀងរហូត។ ទ្រង់ក៏បានសន្យាផងដែរថា ពូជពង្សរបស់ស្តេច

ដាវីឌនឹងសាងសង់ព្រះវិហាររបស់ព្រះនៅក្នុងយេរូសាឡិម។ មុនដំបូងសេចក្តីសន្យានេះត្រូវបានបំពេញសំរេចជាដំបូងតាមរយៈស្តេចសាឡូម៉ូន ដែលបានសាងសង់ព្រះវិហារ។ បន្ទាប់ពីស្តេចសាឡូម៉ូនមក នគរត្រូវបានបែងចែកជាពីរផ្នែក គឺនគរខាងជើងហៅថា អ៊ីស្រាអែល ហើយនគរខាងត្បូងហៅថា យូដា ដែលមានក្រុងយេរូសាឡិមជារាជធានី។

ចំនុចត្រង់នេះមានសារៈសំខាន់ណាស់ ក្នុងការយល់អំពីកណ្ឌអេម៉ុស។ ហោរាអេម៉ុសបានប្រកាសថា អ៊ីស្រាអែលមិនបានធ្វើតាមការត្រាស់ហៅរបស់ខ្លួន ក្នុងការធ្វើជាជាតិសាសន៍បរិសុទ្ធ និងជាពន្លឺដល់ជាតិសាសន៍ដទៃទាំងអស់ទេ ហើយព្រះពិតជានឹងដាក់ការជំនុំជំរះលើពួកគេ ហើយនិងបញ្ជូនពួកគេចេញពីទឹកដី។ ដូច្នេះ ការជំនុំជំរះ ដែលព្រះបានប្រកាសតាមរយៈហោរាអេម៉ុស ត្រូវបានព្រមានរួចហើយនៅក្នុងកណ្ឌចោទិយកថា។ ការព្រមានពីសម័យមុនទាំងនេះគឺជាមូលដ្ឋានគ្រឹះនៃការប្រកាសរបស់ហោរាអេម៉ុស។

## ២. តើគោលបំណងរបស់កណ្ឌអេម៉ុសសំរាប់អ្នកអានដើមដំបូងក្នុងសម័យព្រះគម្ពីរសញ្ញាចាស់គឺជាអ្វី?

ហោរាអេម៉ុសបានទទួលព្រះរាជសារមួយ សម្រាប់ប្រជារាស្ត្ររបស់ព្រះ ដែលរស់នៅមុនពេលការនិរទេសគឺថាព្រះទ្រង់មិនសព្វព្រះហឫទ័យចំពោះការថ្វាយបង្គំរបស់ពួកគេទេ ពោលគឺពួកគេគួរតែប្រែចិត្ត។ អេម៉ុសបានព្រមានគេថា បើសិនពួកគេមិនប្រែចិត្តទេ នោះពួកគេនឹងប្រឈមមុខនឹងការវិនិច្ឆ័យ បន្ទាប់មក គាត់បានប្រកាសថា ការវិនិច្ឆ័យរបស់ព្រះនឹងមកជាពិត។ ឃ្លាដែលពិពណ៌នាអំពីការជំនុំជំរះនេះគឺ «ថ្ងៃរបស់ព្រះអម្ចាស់» និង «ថ្ងៃនោះ» ដែលសំដៅទៅលើថ្ងៃរបស់ព្រះអម្ចាស់ (២:១៦; ៨:៣,៩-១៣; ៥:១៨-២០)។ គាត់ក៏បានប្រាប់ផងដែរថាអនាគតគេនឹងពោរពេញដោយសេចក្តីសង្ឃឹម ពីព្រោះព្រះយេហូវ៉ានឹងសង្គ្រោះពួកគេនៅ«ថ្ងៃនោះ» ផងដែរ (៩:១១)។

## ៣. តើកណ្ឌអេម៉ុសទាក់ទងនឹងកណ្ឌផ្សេងៗទៀត ដែលមានក្នុងព្រះគម្ពីរបន្ទាប់ពីកណ្ឌនេះយ៉ាងដូចម្តេច?

មានរបៀបខ្លះដែលកណ្ឌអេម៉ុសទាក់ទំនងនឹងកណ្ឌផ្សេងៗ ដែលមានបន្ទាប់ពីវា។

ទំនាយអំពីការវិនាសនិងការនិរទេសសំរាប់អ៊ីស្រាអែលត្រូវបានបំពេញសំរេចនៅពីរបីទសវត្សក្រោយមក។ ទំនាយអំពីការស្តារឡើងវិញនៅក្នុង ៩:១១-១៥ ជាដំបូងត្រូវបានបំពេញសម្រេចនៅពេលជនជាតិអ៊ីស្រាអែលបានវិលត្រឡប់មកពីការនិរទេសវិញ ប៉ុន្តែជាចុងក្រោយចង្អុលទៅកាន់សម្ព័ន្ធមេត្រីថ្មីតាមរយៈព្រះយេស៊ូវ ជាពេលមនុស្សគ្រប់ជាតិសាសន៍ទាំងអស់នឹងមកឯព្រះ (អេម៉ុស ៩:១២)។ ការដកស្រង់របស់ព្រះគម្ពីរសញ្ញាថ្មីចេញពីកណ្ឌអេម៉ុសសំដៅទៅលើ ទាំងជនជាតិអ៊ីស្រាអែល និងពួកសាសន៍ដទៃ។ នៅពេលស្ទេផានបានដកស្រង់សំដីរបស់ហោរាអេម៉ុសនៅក្នុងកិច្ចការ ៧ គាត់ប្រើពាក្យសំដីរបស់អេម៉ុសនិយាយទៅកាន់អ៊ីស្រាអែល។ នៅក្នុងកិច្ចការ ១៥:១៦-១៧ សំដៅទៅលើកណ្ឌអេម៉ុសនៅក្នុងរបៀបមួយ ដែលបង្ហាញថា កណ្ឌអេម៉ុសបានមានព្រះរាជ

សារមួយទៅកាន់គ្រួសារទាំងអស់នៅលើផែនដីនេះ (ពួកសាសន៍ដទៃ)។ ដូច្នេះ កណ្ឌអេម៉ុសមានសារ ដែលត្រូវប្រកាសមកដល់ទាំងអ៊ីស្រាអែលនិងលោកិយទាំងមូលផងដែរ។

ការលើកទីលំនៅរបស់ដាវីឌឡើងវិញ (៩:១១) ជាចុងក្រោយត្រូវបានបំពេញសំរេចដោយព្រះយេស៊ូវ ដែលជាពូជពង្សរបស់ស្តេចដាវីឌ ដែលគ្រប់គ្រងលើបល្ល័ង្ករបស់ដាវីឌជារៀងរហូត។

## ៤. តើកណ្ឌអេសាយបង្រៀនយើងអ្វីខ្លះអំពីព្រះ?

តាមការរៀបរាប់ខាងលើនេះ យើងមើលឃើញថា កណ្ឌអេម៉ុសបង្រៀនថាៈ

- ព្រះទ្រង់បរិសុទ្ធ និងទតឃើញគ្រប់ទាំងអស់ ហើយដាក់ទណ្ឌកម្មចំពោះអំពើបាប។
- ទ្រង់គ្រប់គ្រងប្រវត្តិសាស្ត្ររបស់មនុស្សជាតិដោយព្រះបន្ទូលរបស់ទ្រង់។ ទំនាយរបស់អេម៉ុសបានកើតឡើងបន្ទាប់មក។
- ដោយសេចក្តីមេត្តាករុណារបស់ទ្រង់ ព្រះបានបញ្ជូនពួកហោរារបស់ទ្រង់មកឯរាស្ត្ររបស់ទ្រង់ ដើម្បីប្រាប់ពួកគេអោយប្រែចិត្ត។ ដូចគ្នាផងដែរ សព្វថ្ងៃនេះ ដោយសេចក្តីមេត្តាករុណារបស់ទ្រង់ ព្រះបញ្ជូនគ្រីស្ទបរិស័ទទៅក្នុងលោកិយ ដើម្បីប្រកាសដំណឹងល្អអោយមនុស្សបានជឿលើព្រះយេស៊ូវ និងងាកបែរមករកទ្រង់វិញ។
- ព្រះទ្រង់ស្មោះត្រង់ចំពោះសេចក្តីសន្យារបស់ទ្រង់។
- ចង់អោយមនុស្សស្តាប់បង្គាប់ព្រះបន្ទូលរបស់ទ្រង់ មិនមែនគ្រាន់តែថ្វាយដង្វាយនោះទេ។
- ព្រះយកព្រះទ័យទុកដាក់លើគ្រប់ផ្នែកទាំងអស់នៅក្នុងសង្គមហើយព្រះអង្គសព្វព្រះហឫទ័យនឹងសេចក្តីយុត្តិធម៌។
- ព្រះមានសេចក្តីមេត្តាករុណា។ ទោះបីជា រាស្ត្ររបស់ទ្រង់បានបះបោរប្រឆាំងនឹងព្រះអង្គក្តី ក៏ទ្រង់នៅតែសំដែងសេចក្តីមេត្តាករុណាហើយសន្យាថា នៅពេលអនាគតទ្រង់នឹងសង្គ្រោះគេ។
- ព្រះហឫទ័យរបស់ព្រះអង្គគឺសង្គ្រោះសាសន៍ដទៃផងដែរ (៩:១២)។

## ៥. តើកណ្ឌនេះបង្រៀនយើងអ្វីខ្លះអំពីមនុស្ស?

- មនុស្សបះបោរប្រឆាំងនឹងព្រះ ហើយសមនឹងទទួលទណ្ឌកម្មពីទ្រង់។
- មនុស្សចូលចិត្តថ្វាយបង្គំរូបព្រះ។ យើងដើរតាមរូបព្រះផ្សេងៗលឿនជាងការដើរតាមព្រះដ៏ពិត (៥:២៦)។
- មនុស្សមានចិត្តសាហាវ ហើយគាបសង្កត់រាស្ត្ររបស់ព្រះជាញឹកញាប់ (២:៧; ៣:៩; ៤:១; ៥:១២)។
- ជារឿយៗ មនុស្សអនុវត្តតាមសាសនានិងពិធីបុណ្យសាសនា ប៉ុន្តែចិត្តរបស់ពួកគេគឺនៅឆ្ងាយពីព្រះជាម្ចាស់ណាស់ (៥:២១-២៧)។

## ៦. តើកណ្ឌនេះអនុវត្តមកកាន់គ្រីស្ទបរិស័ទសព្វថ្ងៃយ៉ាងដូចម្ដេច?

កណ្ឌអេម៉ុសទាក់ទងនឹងជីវិតរបស់យើងនៅសព្វថ្ងៃនេះនៅក្នុងរបៀបជាច្រើន។

១. កណ្ឌអេម៉ុសជួយយើងអោយយល់អំពីដំណឹងល្អ។ ទីមួយ កណ្ឌនេះបង្ហាញថា លោកិយទាំងមូលស្ថិតនៅក្រោមការវិនិច្ឆ័យរបស់ព្រះ ហើយត្រូវការនូវការសង្គ្រោះចេញពីការវិនិច្ឆ័យនោះ។ ហោរាអេម៉ុសប្រើសំនួនសេចក្ដីថា «ថ្ងៃនៃព្រះអម្ចាស់» (អេម៉ុស ៥:១៨-២០) ដើម្បីបរិយាយអំពីការវិនិច្ឆ័យនេះ ហើយព្រះគម្ពីរសញ្ញាថ្មីប្រើសំនួនសេចក្ដីនេះ ហើយផ្លាស់ប្ដូរទៅជា «ថ្ងៃនៃព្រះយេស៊ូវគ្រីស្ទ» ដើម្បីបរិយាយអំពីថ្ងៃ ដែលព្រះយេស៊ូវនឹងយាងត្រឡប់មកវិញ ហើយនាំការវិនិច្ឆ័យរបស់ព្រះមកលើលោកិយទាំងមូលនេះ។ ៩:១១-១៥ ប្រាប់យើងថា ព្រះនឹងមិនគ្រាន់តែស្ដារាស្រ្ដរបស់ទ្រង់ឡើងវិញប៉ុណ្ណោះទេ ប៉ុន្តែ ដល់មនុស្សមកពីគ្រប់ជាតិសាសន៍ទាំងអស់ ដែលជាអ្នកហៅព្រះនាមរបស់ទ្រង់ (ខ.១២)។ ដូច្នេះ ឥឡូវនេះទ្រង់បានប្រទានពរ និងស្ដារអស់អ្នកណា ដែលនៅក្រោមការវិនិច្ឆ័យរបស់ព្រះឡើងវិញ។ គ្រីស្ទបរិស័ទសព្វថ្ងៃនេះមកពីជាតិសាសន៍ទាំងអស់គឺជាការបំពេញសំរេចនៃទំនាយនេះ។

២. អេម៉ុសនិយាយទាស់នឹងអយុត្តិធម៌  ហើយព្រះនៅតែមានព្រះទ័យទុកដាក់ដូចគ្នានៅសព្វថ្ងៃនេះ។ ជារឿយៗគ្រីស្ទបរិស័ទដកស្រង់ការសង្កត់ធ្ងន់លើយុត្តិធម៌ចេញពីកណ្ឌអេម៉ុស ហើយនេះជាការត្រឹមត្រូវ។ ប៉ុន្តែយើងត្រូវតែរៀនប្រើការសង្កត់ធ្ងន់នេះអោយបានត្រឹមត្រូវ។ ការថ្កោលទោសរបស់ហោរាអេម៉ុសចំពោះជីវិតមានគ្រឿងប្រណិតគ្រប់យ៉ាង និងការព្រងើយកន្តើយ ចំពោះពួកអ្នកក្រីក្ររបស់អ៊ីស្រាអែល មិនគួរក្លាយជាស្នូលនៃសាររបស់គ្រីស្ទបរិស័ទឡើយ។ យើងមិនអាចកាត់បន្ថយដំណឹងល្អមកត្រឹមសីលធម៌ប៉ុណ្ណោះនោះទេ បើទោះជាយើងគួរតែយកចិត្តទុកដាក់ចំពោះយុត្តិធម៌ក៏ដោយ។ ស្នូលនៃជំនឿគ្រីស្ទបរិស័ទគឺជាដំណឹងល្អ។  បើសិនជាយើងជឿថាដំណឹងល្អគ្រាន់តែត្រាស់ហៅយើងអោយមានសេចក្ដីមេត្តាករុណាដល់អ្នកដទៃតែប៉ុណ្ណោះ ហើយយើងមិនយកសេចក្ដីមេត្តាករុណារបស់ព្រះអង្គ ចំពោះយើងនៅលើឈើឆ្កាងទុកជាមូលដ្ឋានគ្រឹះសម្រាប់អំពើនេះទេ នោះយើងបានខាតបង់ដំណឹងល្អហើយ។

៤. ការប្រើ *ទីកន្លែង* នៅក្នុងកណ្ឌអេម៉ុសបើកសំដែងអំពីបេសកកម្មរបស់ព្រះនៅក្នុងលោកិយនេះ។ ទីកន្លែងមានន័យលើសពីទីតាំង។ អេម៉ុសប្រើពាក្យជាច្រើនសំរាប់ទីកន្លែង (ឧទាហរណ៍ ផ្ទះ ទីលំនៅ ទីក្រុង) ដើម្បីតំណាងអោយទំនាក់ទំនងរបស់មនុស្សជាមួយព្រះ ទោះជាពួកគេនៅជិតស្និទ្ធ ឬនៅឆ្ងាយពីទ្រង់។ កាលណាយើងយល់អំពីសារៈសំខាន់នៃ *ទីកន្លែង* នៅក្នុងកណ្ឌអេម៉ុស *ទីកន្លែង*នឹងជួយយើងអោយកាន់តែយល់បានប្រសើរអំពីព្រះរាជសាររបស់កណ្ឌ និងបេសកកម្មរបស់យើងនៅក្នុងលោកិយនេះ។ ការដកស្រង់ពីរដងរបស់ព្រះគម្ពីរសញ្ញាថ្មីចេញ

ពីកណ្ឌអេម៉ុស ទីកន្លែងទាក់ទងនឹងគ្រួសាររបស់ព្រះ។ នៅក្នុងកិច្ចការ ៧ ស្ទេផានប្រើកណ្ឌអេម៉ុស ដើម្បីបង្ហាញថា ព្រះជាម្ចាស់វិនិច្ឆ័យគ្រួសាររបស់ទ្រង់ (រាស្រ្តរបស់ទ្រង់) ពីព្រោះពួកគេយកសុខុមាលភាពរបស់ពួកគេជាអាទិភាពជាងនគរនិងការគ្រប់គ្រងរបស់ព្រះ។ ក្រោយមកនៅក្នុងកិច្ចការ ១៥ យ៉ាកុបដកស្រង់ពីកណ្ឌអេម៉ុស ហើយ *ទីកន្លែង*មានភាពសំខាន់ចាំបាច់ម្តងទៀត។ «ទីលំនៅរបស់ដាវីឌ» និង «សង់ត្រង់កន្លែងបាក់បែក» (កិច្ចការ ១៥:១៦ សូមមើលអេម៉ុស ៩:១១-១២) សំដៅលើផែនការណ៍របស់ព្រះជាម្ចាស់ ក្នុងការតាំងគ្រួសាររបស់ទ្រង់ឡើងវិញចេញពីចំណោមជាតិសាសន៍ទាំងអស់នៅលើផែនដីនេះ។